01226157

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 04 / 2016
ម៉ោង (Time/Heure): 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E401

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**

សាធារណៈ / Public

ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៦

**ជូនចំពោះ៖ ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖ លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖ សេចក្តីសម្រេចទទួលយកឯកសារ D175/3.43 ជាឯកសារភ័ស្តុតាង**

១. នៅក្នុងសវនាការ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចទទួលយកឯកសារ D175/3.43 ជាឯកសារភ័ស្តុតាង។ ឯកសារនេះគឺជាចម្លើយរបស់សាក្សីដែលមានរហស្សនាម 2-TCW-827 ដែលបានផ្តល់ដល់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៩។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះធ្វើឡើងបន្ទាប់ពីមានការយោងដល់ឯកសារនេះពីសំណាក់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅអំឡុងពេលសួរដេញដោលសាក្សីដែលមានរហស្សនាម 2-TCW-827 (សេចក្តីព្រាងប្រតិចារឹកសវនាការថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ៣៨-៤០)។ នាពេលនេះ អង្គជំនុំជម្រះផ្តល់នូវសំអាងហេតុពេញលេញចំពោះសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួន។

២. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចទទួលយកនូវភ័ស្តុតាងដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលឯកសារទាំងនោះ*តាមការវិភាគបឋម* គោរពតាមបទដ្ឋាននៃភាពជាប់ពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង យថាភាព

ដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះធ្វើសេចក្ដីសម្រេចចំពោះសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣)។ វិធាន ៨៧(៤) ក៏តម្រូវផងដែរថា គ្រប់ភាគីត្រូវតែបញ្ជាក់មូលហេតុនៃការស្នើសុំទទួលយកភស្តុតាងថ្មីឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្ដើមជំនុំជម្រះ ឬ មិនអាចរកឃើញបន្ទាប់ពីបានបំពេញការងារដោយយកចិត្តទុកដាក់។ ប៉ុន្តែនៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកភស្តុតាងដែលមិនបំពេញតាមលក្ខខណ្ឌតម្រូវទាំងនេះដែរ ជាពិសេសនៅពេលដែលភស្តុតាងនោះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងឯកសារដែលអង្គជំនុំជម្រះមានរួច-ហើយ ហើយដែលផលប្រយោជន៍យុត្តិធម៌តម្រូវថា ប្រភពនៃឯកសារទាំងនោះត្រូវយកមកវាយតម្លៃរួមគ្នា។ម្យ៉ាងវិញទៀត ឯកសារដែលបានស្នើសុំនោះគឺជាឯកសារដោះបន្ទុកដែលតម្រូវឱ្យមានការវាយតម្លៃរួមគ្នាដើម្បីជៀសវាងការសម្រេចសេចក្ដីដោយអយុត្តិធម៌ (ឯកសារ E276/2 កថាខណ្ឌ២ ដែលយោងដល់ឯកសារ E190 និង E172/24/5/1; ឯកសារ E260, កថា-ខណ្ឌ ៥)។

៣. អង្គជំនុំជម្រះយល់ឃើញថា ការទទួលយកឯកសារ D175/3.43 ជាឯកសារភស្តុតាង គឺជាប្រយោជន៍យុត្តិធម៌។ នៅក្នុងឯកសារនេះ សាក្សី 2-TCW-827 ផ្ដល់នូវដំណើររឿងដែលគាត់បានឆ្លងកាត់ក្នុងនាមជាគ្រូសាសនាអ៊ីស្លាម និង មេដឹកនាំសាសនា នៅភូមិស្ពឺ នៅមុន និងអំឡុងពេលនៃរបបខ្មែរក្រហម។ នៅក្នុងចម្លើយរបស់គាត់ សាក្សី 2-TCW-827 ផ្ដល់នូវព័ត៌មានដែលពាក់ព័ន្ធនឹងការចាប់ខ្លួន ការសម្លាប់ ការជម្លៀស និង ការបំបែកប្រជាជនចាម ព្រមទាំងការធ្វើបាបជនជាតិចាម ហើយកាន់តែទូទៅជាងនេះទៀតនោះគឺ អំពីគោលនយោបាយតឹងរ៉ឹងទៅលើប្រពៃណី សាសនា និង វប្បធម៌របស់ជនជាតិចាម (ឯកសារ D175/3.43 ទំព័រ ៣-៥, ៩-១១)។ សាក្សី 2-TCW-827 ក៏យោងផងដែរទៅលើកិច្ចប្រជុំមួយនៅបុសខ្នុរ ដែលនៅក្នុងកិច្ចប្រជុំនោះកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមបានកត់សម្គាល់ថា សត្រូវធំជាងគេរបស់អង្គការ គឺពួកចាម ហើយត្រូវតែកម្ទេច (ឯកសារ D175/3.43, ទំព័រ ៤-៨)។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ចម្លើយនេះគឺមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត និង មានការពាក់ព័ន្ធជាបឋមទៅនឹងសំណុំរឿង ០០២/០២។

៤. អង្គជំនុំជម្រះសូមរំឭកថា តាមការអនុវត្តជាក់ស្ដែងកន្លងមក អង្គជំនុំជម្រះបានទទួលយកជាឯកសារភស្តុតាងនូវចម្លើយសាក្សីដែលបានផ្ដល់កិច្ចសម្ភាសន៍មុនកាលបរិច្ឆេទ ដែលពួកគេ

ត្រូវផ្តល់សក្ខីកម្ម។ នៅក្នុងករណីនេះ ចម្លើយដែលសួរដោយលោក អ៊ីសា ខស្មាន នៃមជ្ឈមណ្ឌលឯកសារកម្ពុជា គឺបំពេញទៅតាមលក្ខខណ្ឌនៃភាពអាចជឿជាក់បាន និង យថាភាព *តាមការវិភាគបឋម*។

៥. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា លក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញ និង ទទួលយកឯកសារ D175/3.43 ជាឯកសារភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២។ លេខសម្គាល់ E3/9750 ត្រូវបានកំណត់ជាលេខឯកសារនៃចម្លើយខាងលើនេះ។